# មេរៀនទី ៤៨: ព្រះការពារលោកម៉ូសេ

## និក្ខមនំ ១:១-២:១០

**គោលបំណង៖** ព្រះតែងតែការពារយើង។

**ខគម្ពីរចងចាំ៖ ទំនុកដំកើង ៤៦:១** *"ព្រះទ្រង់ជាទីពឹងជ្រក ក៏ជាកំឡាំងនៃយើងខ្ញុំ ជាជំនួយដែលនៅជាប់ជាមួយក្នុងគ្រាអាសន្ន។"*

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

ជីវិតអាចនឹងពិបាក និងមានគ្រោះថ្នាក់។ ព្រះនឹងការពារអស់អ្នកណាដែលទុកចិត្ត និងដើរតាមព្រះរាជបុត្រារបស់ព្រះអង្គគឺព្រះយេស៊ូវគ្រីស្ទ។ នៅពេលដែលជីវិតម៉ូសេជួបគ្រោះថ្នាក់ ព្រះបានការពារគាត់តាមវិធីបែបច្នៃប្រឌិតបំផុត។ តើអ្នកងអាចចងចាំពីការការពារដ៏អស្ចារ្យរបស់ព្រះនៅក្នុងជីវិតរបស់អ្នក ឬក៏នៅក្នុងជីវិតរបស់នរណាម្នាក់ដែលអ្នកស្គាល់បានទេ? ថ្ងៃនេះ សូមអរព្រះគុណព្រះសំរាប់ក្តីស្រលាញ់ និងការការពារមើលថែអ្នក កូនសិស្សរបស់អ្នក និងមនុស្សដែលអ្នកស្រលាញ់។

**ចំរៀង៖** ១. កូនតូចៗអើយ ២.ព្រះអង្គនៃយើងទ្រង់ខ្លាំងពូកែ ៣. ពេលខ្យល់ព្យុះបក់ខ្លាំង

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

### ៣. ល្បែងកំសាន្ត «រាប់សរសៃសក់»



១. តើអ្នកគិតថានៅលើក្បាលរបស់អ្នកមានសក់ប៉ុន្មានសរសៃ? តើធ្វើដូចម្តេចទើបអាចដឹងថាយើងមានសក់ប៉ុន្មានសរសៃនោះ? យើងអាចរាប់វាបាន! អញ្ចឹងតោះ! យើងរាប់ទាំងអស់គ្នា។ អ្នកណាដែលអាចរាប់សរសៃសក់បាននឹងឈ្នះ!

- ឲ្យសិស្សចាប់ដៃគូ រួចឲ្យពួកគេព្យាយាមរាប់សក់ឲ្យគ្នាទៅវិញទៅមក។

២. ប្រហែលជា ១នាទី គ្រូសួរទៅកាន់សិស្សក្រែងលោមានសិស្សខ្លះអាចរាប់សរសៃសក់អស់។ វាមិនអាចទៅរួចទេក្នុងការដែលរាប់សរសៃសក់អស់នោះ ទាល់តែប្រើពេលយូរខ្លាំងណាស់ទើបអាចរាប់បាន។

៣.ប៉ុន្តែអ្វីដែលជារឿងដ៏អស្ចារ្យនោះគឺព្រះទ្រង់ដឹងច្បាស់ថាមនុស្សម្នាក់ៗនៅលើផែនដីនេះមានសក់ប៉ុន្មានសរសៃ ព្រះរបស់យើងទ្រង់អស្ចារ្យណាស់។

### ៤. ការណែនាំមេរៀន

ព្រះរបស់យើងទ្រង់ជ្រាបគ្រប់ការទាំងអស់ ទ្រង់មើលថែយើងដោយការការពារ ដឹកនាំ ផ្គត់ផ្គង់ និងជួយយើង។ ព្រះអង្គធ្វើដូច្នេះព្រោះទ្រង់ស្រលាញ់យើង។ ទ្រង់កំពុងធ្វើការជាច្រើននៅគ្រប់ទីកន្លែងក្នុងផែនដីនេះ។ ព្រះអង្គមិនមែនគ្រាន់តែទតមើលយើងដែលកំពុងនៅក្នុងថ្នាក់រៀននេះទេ ទ្រង់ក៏កំពុងតែទតមើលមកមនុស្សគ្រប់គ្នានៅលើ

ផែនដីនេះដែរ។ ព្រះអង្គមើលថែកូននៅថ្ងៃនេះ! ព្រះអង្គស្រឡាញ់កូន ហើយទ្រង់ខ្វល់ខ្វាយពីរឿងគ្រប់យ៉ាងដែលកូនធ្វើមិនថាការនោះតូចឬធំនោះទេ សូម្បីតែពេលកូនកំពុងដុសធ្មេញ ឬកំពុងលេងជាមួយមិត្តភក្តិ ឬក៏ពេលកូនកំពុងប្រលងនៅក្នុងសាលាក៏ដោយ។ ព្រះអង្គមិនដែលឈប់ទតមើលមកកូនៗនោះទេ។ សាច់រឿងនៅក្នុងព្រះគម្ពីរថ្ងៃនេះបង្ហាញយើងពីរបៀបដែលព្រះទ្រង់ទតមើលមកយើង ទោះបីជាក្នុងគ្រាដែលយើងលំបាកក៏ដោយ។ **និក្ខមនំ ១:១-២:១០** គឺនិយាយអំពីគ្រាដ៏លំបាកក្នុងជីវិតរបស់ម៉ូសេតាំងពីគាត់នៅជាកូនង៉ែតនៅឡើយ។ ដែលនៅពេលនោះរាស្ត្ររបស់ព្រះជួបទុក្ខលំបាកជាខ្លាំង! ថ្ងៃនេះនឹងយើងសិក្សាជាមួយគ្នាពីរបៀបដែលព្រះអង្គបានការពារលោកម៉ូសេ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

នៅក្នុងព្រះគម្ពីរនិក្ខមនំបង្ហាញថាប្រជាជនអ៊ីស្រាអែលបានជួបទុក្ខលំបាកដ៏ធំមួយ។ ផារ៉ោនជាស្តេច អេស៊ីព្ទបានឃើញថា មានប្រជាជនអ៊ីស្រាអែលជាច្រើនកំពុងរស់នៅលើទឹកដីរបស់គាត់។ ស្តេចផារ៉ោនប្រាកដក្នុងចិត្តថាប្រជាជនអ៊ីស្រាអែលនឹងងើបឡើងបះបោរ និងកាន់កាប់លើទឹកដីរបស់គាត់។ ដូច្នេះគាត់ក៏បានប្រាប់ទៅឆ្មបទាំងអស់ថា ពេលទៅសម្រាលកូនឱ្យជាតិអ៊ីស្រាអែល បើជាកូនប្រុសត្រូវតែសម្លាប់ចោលទាំងអស់។ តើកូនគិតថាឆ្មបទាំងនោះធ្វើតាមបង្គាប់ស្តេចផារ៉ោនដែរឬទេ? អត់ទេ! ព្រោះពួកគាត់ទាំងនោះកោតខ្លាចព្រះ ពួកគាត់មិនចង់មានបញ្ហាធំជាមួយនឹងព្រះទេ។ នេះជារឿងល្អសម្រាប់លោកម៉ូសេ ពីព្រោះនៅពេលដែលគាត់ចាប់កំណើត ម្តាយរបស់គាត់ បានព្យាយាមលាក់គាត់មិនឲ្យស្តេចផារ៉ោនដឹង រហូតដល់គាត់មិនអាចលាក់បន្តទៀតបាន។

ដូច្នេះហើយ ម្តាយម៉ូសេបានយកគាត់ទៅដាក់ក្នុងកន្ត្រកមួយដែលមិនជ្រាបទឹក ហើយបណ្តែតនៅក្នុងទន្លេ។ នាងដឹងច្បាស់ថា ព្រះនឹងតាមមើលថែម៉ូសេកូនរបស់នាង ហើយព្រះអង្គពិតជាការពារគាត់មែន! បុត្រីរបស់ផារ៉ោនដែលជាព្រះនាងនៃប្រទេសអេស៊ីព្ទបានឃើញម៉ូសេ ហើយក៏យកម៉ូសេមកចិញ្ចឹមធ្វើជាបុត្ររបស់គាត់នៅក្នុងរាជវាំង។

## ៦. សំនួរពិភាក្សា

១. តើស្តេចអេស៊ីព្ទឈ្មោះអ្វី? *ផារ៉ោន*

២. តើផារ៉ោនបានធ្វើអ្វីដាក់ជនជាតិអ៊ីស្រាអែល? *សំឡាប់កូនក្មេងប្រុសៗទាំងអស់*

៣. តើម្តាយម៉ូសេព្យាយាមប្រើវិធីអ្វីដើម្បីសង្គ្រោះម៉ូសេ?
*គាត់ដាក់ម៉ូសេនៅក្នុងកន្ត្រក ហើយគាត់អធិស្ឋានសុំឲ្យព្រះអង្គតាមការពារម៉ូសេ*

៤. តើព្រះការពារម៉ូសេដោយរបៀបណា? *បុត្រីស្តេចផារ៉ោន*

៥. តើប្អូនៗដឹងថាព្រះជួយប្អូនៗដោយរបៀបណា? *សូមឲ្យកុមារឆ្លើយ*

**៧. ល្បែងកំសាន្ត** **«ល្បែងឧបសគ្គ»**



១ .ម៉ូសេមានឧបសគ្គជាច្រើននៅក្នុងជីវិតរបស់គាត់ប៉ុន្តែព្រះបានដឹងពីបញ្ហារបស់ម៉ូសេហើយបានជួយគាត់។

២. ចែកកុមារជា២ក្រុម ហើយរៀបចំដាក់ឧបសគ្គជាច្រើននៅក្នុងថ្នាក់រៀន ដោយប្រើកៅអី ឬ របស់ក្មេងលេងជាដើម

៣. យកក្រណាត់មកចងបិទភ្នែកក្រុមទី១ ហើយឲ្យគេដើរឆ្លងកាត់បន្ទប់ដោយមិនឲ្យប៉ះនូវឧបសគ្គណាមួយឡើយ។ ពួកគេអាចមើលឃើញពីទីតាំងរបស់ឧបសគ្គទាំងនោះមុននឹងចងភ្នែក ហើយត្រូវរកវិធីធ្វើយ៉ាងណាដើម្បីកុំឲ្យប៉ះឧបសគ្គពេលគេដើរឆ្លងកាត់។



៤. នៅពេលដែលក្រុមទី១ កំពុងត្រូវបានគេចងបិទភ្នែក ក្រុមទី២ត្រូវយកឧបសគ្គចេញដោយស្ងៀមស្ងាត់ (*កុំឲ្យឮសម្លេង*)

៥. គ្រូប្រាប់ក្រុមទី ១ ឲ្យដើរឆ្លងកាត់បន្ទប់ដោយមិនឲ្យប៉ះឧបសគ្គ (*ប៉ុន្តែមិនមានឧបសគ្គទេនៅក្នុងបន្ទប់ទេ*) ។

៦. នៅពេលក្រុមទី ១ ទៅដល់ទីម្ខាងទៀតសូមឲ្យក្មេងៗ ស្រាយក្រណាត់រុំភ្នែកចេញ។

៧. ពួកគេនឹងឃើញថាមិនមានឧបសគ្គនៅក្នុងផ្លូវរបស់ពួកគេទេ។

៨. ពេលខ្លះជីវិតរបស់យើងក៏ស្រដៀងគ្នាដែរ វាហាក់ដូចជាមានឧបសគ្គនិងរឿងលំបាកជាច្រើននៅក្នុងជីវិតរបស់យើង។ ប៉ុន្តែបើយើងទុកចិត្តព្រះឲ្យទ្រង់មើលថៃយើង នោះយើងនឹងឃើញថា ទ្រង់ជួយយើងឲ្យឆ្លងកាត់ឧបសគ្គឬក៏ដកហូតយកឧបសគ្គទាំងនោះចេញតែម្តង។

**៨. ខគម្ពីរចងចាំ** **ទំនុកដំកើង ៤៦:១**

**៩. ហាត្ថកម្ម** សូមផាត់ពណ៌រូបភាព **«ព្រះការពារម៉ូសេ»**

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*

# ព្រះការពារលោកម៉ូសេ

